ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ៩៥/១២-វីនស៊ីងចិច

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **ស៊ីន គីមស៊ាន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន វីនស៊ីងចិច (ខេមបូឌា) ខូអិលធីឌី**

អាសយដ្ឋាន ៖ ភូមិជម្ពូវ័ន្ត សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៨៩ ៦៩៩ ៩៥៨ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមប្រជុំមុនសវនាការ ៖

| | |
|---|---|
| ១- លោក លឹម អេង | ទីប្រឹក្សាក្រុមហ៊ុន |
| ២- លោក ឈិន សៅ | ប្រធានរដ្ឋបាល |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖- **សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា**

- **សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ ក្រុមហ៊ុន វីនស៊ីងចិច**

អាសយដ្ឋាន ៖ ភូមិជម្ពូវ័ន្ត សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១៦ ២៣៥ ៤៥៨ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតចូលរួមប្រជុំមុនសវនាការ ៖



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥ ២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh◈ Tel/Fax: 855-23 881 824

| | |
|---|---|
| ១- លោក សាន សុផា | មន្រ្តីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ២- លោក ប៊ុត ប៊ុនណា | មន្រ្តីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ៣- លោក ប៉ាល់ លក្ខិណា | ប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃក្រុមហ៊ុន |
| ៤- លោក ម៉ែន វណ្ណា | អនុប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ |
| ៥- លោក វ៉ាន់ ខេមរា | លេខាធិការសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ |
| ៦- លោក ស្វាយ តាក់ | ទីប្រឹក្សាសហជីព |
| ៧- កញ្ញា សេត ផល | សកម្មជនសហជីព |
| ៨- កញ្ញា ទេស ស្រីនាង | កម្មការិនី |
| ៩- កញ្ញា ពេជ្រ មុំ | កម្មការិនី |
| ១០- កញ្ញា សេង ស្រីណូ | កម្មការិនី |
| ១១- កញ្ញា ឡី វណ្ណលីដា | កម្មការិនី |
| ១២- កញ្ញា អ៊ីន ហឿន | កម្មការិនី |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងស្នាក់នៅចំនួន ១៥ ដុល្លារ ក្នុងមួយខែ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមានលទ្ធភាពផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងស្នាក់នៅចំនួន ០៣ ដុល្លារ ក្នុងមួយខែ។

២- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនកាត់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ ដុល្លារ ក្នុងមួយខែ តាមសមាមាត្រចំនួនថ្ងៃដែលកម្មករអវត្តមាន។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ចំពោះប្រាក់រង្វាន់ធ្វើការទៀងទាត់ ក្រុមហ៊ុនអនុវត្តដូចតទៅ បើកម្មករអវត្តមានតិចជាងមួយថ្ងៃ កាត់ ៥០ ភាគរយ និងអវត្តមានមួយថ្ងៃឡើងទៅ កាត់ ១០០ ភាគរយ។

៣- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនបង្កើតមូលនិធិសង្គ្រោះ ដោយផ្តល់លុយដំបូងចំនួន ៣០០ ដុល្លារ សម្រាប់ជួយដល់កម្មករនិយោជិត។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនពុំអាចផ្តល់តាមសំណូមពររបស់កម្មករនិយោជិតទេ។

៤- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់បន្ទប់ប្រជុំសម្រាប់ថ្នាក់ដឹកនាំសហជីព មានតុ កៅអី ទូដាក់ឯកសារច្បាប់ ប្រកាស និងសម្ភារៈការិយាល័យ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនពុំអាចផ្តល់បន្ទប់សម្រាប់សហជីពបានទេ។

៥- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យថ្នាក់ដឹកនាំសហជីព ឬសកម្មជនសហជីព ទៅចូលរួមវគ្គសិក្ខាសាលា ឬដោះស្រាយវិវាទការងារ ដោយរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តតាមប្រកាសលេខ ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១។

៦- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុននៅពេលមានការប្តូរទីតាំងរោងចក្រ ត្រូវតែអនុវត្តនីតិវិធីឱ្យបានច្បាស់លាស់ទៅតាមច្បាប់ស្តីពីការងារ និងអនុសញ្ញារួម។

៧- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុននៅពេលរោងចក្របិទត្រូវតែជូនដំណឹងទៅសហជីពមុនបីខែ ដើម្បីពិភាក្សាអំពីនីតិវិធីនៃការបិទ ដែលចែងក្នុងអនុសញ្ញារួម។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ករណីបើរោងចក្របិទ គឺក្រុមហ៊ុនអនុវត្តតាមច្បាប់ស្តីពីការងារ។

៨- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនពិភាក្សាអំពីនីតិវិធីដែលមានចែងនៅក្នុងអនុសញ្ញារួម ចំពោះការទូទាត់ប្រាក់សំណងក្នុងករណីក្រុមហ៊ុនបិទ ឬផ្ទេរ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ករណីបិទរោងចក្រ ក្រុមហ៊ុនអនុវត្តតាមច្បាប់ស្តីពីការងារ។

៩- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយសម្រាប់កម្មករធ្វើការថែមម៉ោង លើសពីពីរម៉ោង ចំនួន ១000 រៀល។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ចំពោះការធ្វើការថែមម៉ោង ចាប់ពីម៉ោង ១៦ ដល់ម៉ោង ១៨ ក្រុមហ៊ុនអនុវត្តតាមសេចក្តីជូនដំណឹង ០៤១/១១ កប/សជណ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ ករណីថែមម៉ោងដល់ម៉ោង ២០ យប់ ក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយបន្ថែម ចំនួន ១០០០ រៀល ក្នុងមួយម៉ោង។

១០- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនរៀបចំនីតិវិធីនៃការបញ្ឈប់ ឬផ្តាច់កិច្ចសន្យាការងារស្របតាមច្បាប់ និងការព្រមព្រៀង ដែលមានចែងក្នុងកិច្ចព្រមព្រៀង។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ចំពោះការបញ្ឈប់ ឬផ្តាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិត ក្រុមហ៊ុនអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់រោងចក្រ និងច្បាប់ស្តីពីការងារ។

១១- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃទឹកដោះគោ ចំនួន ២០ ដុល្លារ ក្នុងមួយខែ សម្រាប់ស្ត្រីដែលមានកូនតូច ដោយគិតចាប់ពីថ្ងៃសម្រាលកូនរហូតដល់កូនមានអាយុ ១៨ ខែ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនពុំមានលទ្ធភាពផ្តល់ឱ្យឡើយ គឺក្រុមហ៊ុនផ្តល់ពេលមួយម៉ោងក្នុងមួយថ្ងៃ ដើម្បីចេញទៅបំបៅដោះកូន។

១២- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនបញ្ចូលកម្មករដែលមានកិច្ចសន្យាការងារលើសពីពីរឆ្នាំឡើងទៅជាកិច្ចសន្យាការងារគ្មានថិរៈវេលាកំណត់វិញ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុននៅតែអនុវត្តតាមគោលការណ៍ចាស់ដដែល។

១៣- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនដកលោក ឈិន សៅ ជារដ្ឋបាល លោក យ៉ង់ តង់ លោក នៅ ស៊ីណា ជាជំនួយការរដ្ឋបាលចេញពីរោងចក្រ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនអាចដកពួកគាត់ចេញពីរោងចក្របានឡើយ។

THE ARBITRATION COUNCIL

១៤- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនធ្វើការចរចាអនុសញ្ញារួមបន្តទៀត។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុននឹងចាត់តាំងតំណាងរោងចក្រ ដើម្បីធ្វើការចរចាអនុសញ្ញាជាមួយសហជីពស៊ីខៅខូ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិក ក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៣២១ ក.ប/អក/វក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យតន្ត្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទជួបប្រជុំមុនសវនាការ ៖ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១១ (វេលាម៉ោង ១៥ និង ៣០ នាទី រសៀល )។

បញ្ហានៃនីតិវិធី ៖

នៅថ្ងៃទីទី០៧ ខែមីនា ឆ្នាំ២០១២ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់សម្ព័ន្ធសហជីពស៊ីខៅខូ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអរនូវលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ។ បន្ទាប់ពីទទួលបានពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះ ដោយទទួលលទ្ធផលមិនសះជានឹងគ្នា ចំនួន ១៤ ចំណុច លើការទាមទារចំនួន ១៦ ចំណុច។ ចំណុចមិនសះជាចំនួន ១៤ ចំណុចនេះ បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន វីនស៊ីងចិច លេខ ៣២១/១១ ក.ប/អក/វក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ ដដែល កម្មករនិយោជិតបាននាំគ្នាធ្វើកូដកម្ម ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាលេខ ០០៩/១២ កបអ. ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ ឱ្យផ្អាកជាបន្ទាន់ការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្រុមហ៊ុន វីនស៊ីងចិច រហូតដល់នីតិវិធីនៃអាជ្ញា

កណ្តាល ត្រូវបានចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១២ តទៅ តាមវេនរបស់ខ្លួន។

ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ លេខាធិការដ្ឋានក្រុមប្រឹក្សាក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលព័ត៌មានតាមទូរស័ព្ទពីក្រុមហ៊ុន និងបានសាកសួរព័ត៌មានទៅភាគីទាំងពីរ ដោយទទួលព័ត៌មានថា កម្មករនិយោជិតមិនព្រមចូលធ្វើការតាមបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានឱ្យលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលកោះអញ្ជើញភាគីកម្មករនិយោជិត និងក្រុមហ៊ុនមកចូលរួមកិច្ចប្រជុំមុនសវនាការ ដើម្បីសាកសួរព័ត៌មានស្តីពីកូដកម្ម នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ វេលាម៉ោង ១៥ និង ៣០ នាទី រសៀល នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ភាគីទាំងពីរមានវត្តមានតាមការអញ្ជើញ។ ក្នុងកិច្ចប្រជុំមុនសវនាការនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានពន្យល់ប្រាប់ភាគីទាំងពីរអំពីនីតិវិធីសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាល និងស្នើឱ្យភាគីទាំងពីររក្សាភាពស្ងប់ស្ងាត់ ចៀសវាងការធ្វើវិវាទឱ្យកាន់តែធ្ងន់ធ្ងរ។ មានន័យថា កម្មករនិយោជិតត្រូវបញ្ឈប់ការធ្វើកូដកម្ម។ ភាគីសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំមុនសវនាការបញ្ជាក់ថា មកដល់ពេលនេះ កម្មករនិយោជិតមិនព្រមស្តាប់តាមការពន្យល់របស់សហជីពនោះទេ គឺកម្មករនិយោជិតនៅតែជ្រើសរើសបន្តការធ្វើកូដកម្មដដែល ពោលគឺ មកដល់ពេលនេះ កម្មករនិយោជិតនៅតែប្រកាន់ជំហរធ្វើកូដកម្មដដែល។

ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងសម្រេច ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖ គ្មាន

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន វីនស៊ីងចិច លេខ ៣២១ ក.ប/អក/វក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន វីនស៊ីងចិច ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១២។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមកិច្ចប្រជុំមុនសវនាការលេខ ៣២០ កប/អក/វក/លកអ. ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១២ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមកិច្ចប្រជុំមុនសវនាការលេខ ៣២១ កប/អក/វក/លកអ. ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ ។

THE ARBITRATION COUNCIL

**អង្គហេតុ**

- មិនមានការរកឃើញអង្គហេតុទាក់ទងទៅនឹងចំណុចបញ្ហាវិវាទ នៅក្នុងរបាយការណ៍មិនសះជា ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចដំណើរការសវនាការបាន ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនឹងត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ?

ប្រការ២០ នៃប្រកាសលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា " *ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម* " ។

យោងតាមប្រការ២០ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីវិវាទត្រូវផ្អាករាល់វិធានការវិវាទ ដូចជា*<u>កូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទ កាន់តែធ្ងន់ធ្ងរ នៅក្នុងដំណើរការរបស់ក្រុមអាជ្ញាកណ្តាល</u>*។

នៅក្នុងសេចក្តីបញ្ជាមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាភាគីកម្មករកំពុងធ្វើកូដកម្ម ។

ឧទាហរណ៍ នៅក្នុងសំណុំរឿងសេចក្តីបង្គាប់លេខ ០៤/០៤-អិម អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីជូនដំណឹងមួយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខ័ណ្ឌទី៤ នៃសេចក្តីជូនដំណឹងនេះ ចែងថា ៖

" *ដោយពិនិត្យឃើញថា ភាគីនៃវិវាទការងារនេះមិនមានសិទ្ធិធ្វើកូដកម្ម ក្នុងកំឡុងពេលនៃដំណើរការរបស់អាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្តីបង្គាប់លើវិវាទការងាររួមនេះ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដោះស្រាយវិវាទការងាររួមនេះម្តងទៀតបាន នៅពេលណាដែលសហជីពកម្មករនិយោជិតទាំងអស់ឈប់ធ្វើកូដកម្ម* "។

ដូចគ្នាដែរ នៅក្នុងរឿងក្តី ១៨/០៤-សណ្ឋាគារ (កាំបូឌីយ៉ាណា, រ៉ាហ្វែល ឡឺរ៉ូយ៉ាល់, រ៉ាហ្វល ប្រែនូន ឌិ អង្គរ, សាន់វេ, អ៊ិនធើខនធីណេនថល និង សូភីតែល អង្គរ) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទីពីរ ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ២០០៤ ត្រង់ចំណុចទី៩ និងទី១១ នៃសេចក្តីបញ្ជានេះចែងដូចខាងក្រោម ៖

" *ចំណុចទី៩- ចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ តទៅ កម្មករនិយោជិតទាំងអស់ត្រូវបញ្ឈប់កូដកម្ម បាតុកម្ម ឬ ការរំខានណាមួយ នៅក្នុងបរិវេណសណ្ឋាគារនានា ដែលជាភាគីនៃវិវាទនេះ* " ។

" *ចំណុចទី១១- ក្រុមប្រឹក្សាអាជ្ញាកណ្តាលរក្សាសិទ្ធិក្នុងការបញ្ចប់ដំណើរការអាជ្ញាកណ្តាល ករណីដែលភាគីណាមួយបំពានប្រការណាមួយនៃសេចក្តីបញ្ជានេះ* " ។

THE ARBITRATION COUNCIL

នៅក្នុងសំណុំរឿង ៧៧/០៦-ប្រេង់កូ នីតធីង ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទី២ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០០៥ ហើយបានចែងនៅក្នុងចំណុចទី៤ថា នៅក្នុងករណីដែលភាគីកម្មករនិយោជិតបន្តធ្វើកូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនដំណើរការដោះស្រាយវិវាទការងាររួមនេះទេ ។

នៅក្នុងសំណុំរឿង លេខ១១០/១១-ស៊ីម៉ាណូ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានចេញសេចក្តីបង្គាប់ មិនបន្តដំណើរការអាជ្ញាកណ្តាល ដោយមូលហេតុកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មក្នុងកំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែរ ។

ហេតុនេះ ផ្អែកតាមប្រការ២០ នៃប្រកាស ០៩៩ និងការបកស្រាយខាងលើ នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម ដោយមិនព្រមគោរពតាមបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះទេ ពោលគឺពុំបានបង្ហាញពីចេតនាពិតប្រាកដណាមួយថា ភាគីកម្មករនិយោជិតមានបំណងយកវិវាទការងាររួមនេះ មកដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច មិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះទេ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

- មិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ៥៩/១២ - វីនស៊ីងចិច នេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ឹង សុទ្ធី**

ហត្ថលេខា: -----------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ស៊ីន គឹមស៊ាន**

ហត្ថលេខា: -----------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា: -----------------------------------------

THE ARBITRATION COUNCIL